**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

*ថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន

នៅព្រឹកថ្ងៃពុធ ៣រោច ខែពិសាខ ឆ្នាំខាល ត្រីស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំកិច្ចប្រជុំពិភាក្សាលើយុទ្ធសាស្ត្រអឺរ៉ុបរួមស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០២១-២០២៧ រវាងរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអឺរ៉ុប ។ កិច្ចប្រជុំនេះដឹកនាំដោយ **ឯកឧត្តម ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង **លោកជំទាវ Carmen Moreno** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ កិច្ចប្រជុំនេះ មានការចូលរួមពីមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញមកពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលចំនួន ២៩ ស្ថាប័ន និងតំណាងនៃបណ្តាប្រទេសជាសមាជិកសហភាពអឺរ៉ុបប្រមាណ ១០ ប្រទេស រួមទាំងឯកឧត្តម Jacques Pellet ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា និងជាប្រធានក្រុមប្រឹក្សាសហភាពអឺរ៉ុប និងឯកឧត្តម Martin Vavra ឯកអគ្គរដ្ឋទូតសាធារណរដ្ឋឆែកប្រចាំកម្ពុជា ។ គោលដៅចម្បងនៃកិច្ចប្រជុំនេះ គឺដើម្បីពិភាក្សាលើយុទ្ធសាស្ត្រអឺរ៉ុបរួមស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០២១-២០២៧ ។

ឯកឧត្តម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាសហប្រធាននៃកិច្ចប្រជុំបានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះយុទ្ធសាស្ត្រអឺរ៉ុបរួម ដែលជាក្របខ័ណ្ឌគោលនយោបាយរួមរបស់សហភាពអឺរ៉ុប និងប្រទេសសមាជិកដែលតម្រឹមជាមួយនឹងគោលនយោបាយអភិវឌ្ឍន៍របស់កម្ពុជា ព្រមទាំងរំលេចពីការប្តេជ្ញារបស់ដៃគូអឺរ៉ុបក្នុងការរួមចំណែកដល់ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ។ ឯកឧត្តម Jacques Pellet ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជាដែលជាប្រធានក្រុមប្រឹក្សាសហភាពអឺរ៉ុប ក៏បានជម្រាបអង្គប្រជុំផងដែរថា យុទ្ធសាស្ត្រថ្មីនេះមានសង្គតិភាពជាមួយយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា ហើយដៃគូអឺរ៉ុបបានកំណត់អាទិភាពជាសាកលលើការលើកកម្ពស់ថាមពលបៃតង, ការពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគី និងការគោរពសណ្តាប់ធ្នាប់សាកលដែលផ្អែកតាមច្បាប់ ។ យុទ្ធសាស្ត្រថ្មីនេះ នឹងរួមចំណែកដល់ការអនុវត្តរបៀបវារៈឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏ដូចជា

ផ្តល់ការគាំទ្រដល់កម្ពុជា ក្នុងការពង្រឹងការតភ្ជាប់ក្នុងតំបន់អាស៊ាន ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសមាហរណកម្ម ក្នុងតំបន់ និងសកល ។

តាមរយៈយុទ្ធសាស្ត្រនេះ ដៃគូអឺរ៉ុបនឹងផ្តោតលើវិស័យអាទិភាព ៦ រួមមាន÷

១. ការពង្រឹងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

២. ការជំរុញការចូលរួមតាមបែបប្រជាធិបតេយ្យ

៣. ការអភិវឌ្ឍធនធានមនុស្ស

៤. ការពង្រឹងភាពប្រកួតប្រជែងកម្ពុជា ក្នុងទីផ្សារតំបន់ និងសកល

៥. ការលើកកម្ពស់ការអភិវឌ្ឍបៃតងប្រកបដោយចីរភាព

៦. ការពង្រឹងកិច្ចអភិរក្សបេតិកភណ្ឌវប្បធម៌កម្ពុជា

ដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ ដៃគូអឺរ៉ុបបានត្រៀមកញ្ចប់ហិរញ្ញប្បទានប្រមាណ ១ ៤៣២,៦៣ លានអឺរ៉ូ ដោយផ្តោតសំខាន់លើការពង្រឹងការស្តារសង្គម-សេដ្ឋកិច្ច ព្រមទាំងបញ្ហាអន្តរវិស័យ រួមមានសិទ្ធមនុស្ស, សមភាពយេនឌ័រ, ភាពអង់អាចរបស់ស្ត្រី និងយុវជន, ការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព ។ បន្ថែមលើនេះ យុទ្ធសាស្ត្រអឺរ៉ុបរួមក៏នឹងចូលរួមក្នុងការជំរុញឌីជីថលភាវូបនីយកម្មនៅកម្ពុជា និងគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការធានាឱ្យបាននូវដំណោះស្រាយប្រព័ន្ធព័ត៌មានវិទ្យាប្រកបដោយចីរភាព និងសមិតភាព និងអនុលោមភាពតាមបទដ្ឋាន និងស្តង់ដារអន្តរជាតិ ជាពិសេសលើការការពារទិន្នន័យ ។

មុននឹងបញ្ចប់ លោកជំទាវ **Carmen Moreno** បានគូសបញ្ជាក់ពីភាពចាំបាច់ និងភាពពាក់ព័ន្ធរបស់យុទ្ធសាស្ត្រអឺរ៉ុបរួម ក្នុងការអនុវត្តគោលនយោបាយរបស់សហភាពអឺរ៉ុបនៅកម្ពុជា ដែលក្នុងនោះរួមមានយុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិក ឬយុទ្ធសាស្ត្រច្រកសកល ។ លោកជំទាវបានបន្ថែមទៀតថា យុទ្ធសាស្ត្រអឺរ៉ុបរួមស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០២១-២០២៧ នឹងគាំទ្រដៃគូអឺរ៉ុប និងកម្ពុជា, រដ្ឋាភិបាល, សង្គមស៊ីវិល និងវិស័យឯកជន ក្នុងការបង្កើនភាពផ្សារភ្ជាប់ប្រកបដោយចីរភាព ស្របតាមស្តង់ដារបរិស្ថាន និងសង្គម។ ជាចុងបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម **ឈឿង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហភាពអឺរ៉ុប និងដៃគូអឺរ៉ុប ដែលបានបន្តរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍របស់កម្ពុជា ៕